01617725

E443/15

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 06 / 2019
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
**Trial Chamber**
**Chambre de première instance**
លេខ៖ 289 អ.វ.ត.ក./អ.ជ.ស.ដ.

**គោរពជូន**

**លោក ឆាយ វិសុទ្ធ ប្រធានការិយាល័យនៃសារមន្ទីរទួលស្លែង**

**តាមរយៈ៖** ឯកឧត្តមប្រធានស្តីទីការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**កម្មវត្ថុ៖** ចម្លើយតបទៅនឹងលិខិតរបស់លោកដែលស្នើសុំឲ្យអង្គជំនុំជម្រះបញ្ជូនឯកសាររបស់លោកសាស្ត្រាចារ្យ Heynowski ទៅសារមន្ទីរទួលស្លែង

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបថា ខ្ញុំទទួលបានលិខិតរបស់លោក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ ដែលបានស្នើសុំការបញ្ជាក់បំភ្លឺអំពីពេលវេលាដែលអង្គជំនុំជម្រះអាចបញ្ជូនឯកសារមន្ទីរសន្តិសុខ ស-២១ ដែលលោកសាស្ត្រាចារ្យ Walter Heynowski បានប្រគល់ជូនអង្គជំនុំជម្រះសាលាដំបូង ដើម្បីយកទៅរក្សាទុកនៅសារមន្ទីរទួលស្លែងវិញ។

ជាបឋម ខ្ញុំសូមបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមបញ្ជូនឯកសារទាំងអស់ដែលលោកសាស្ត្រាចារ្យ Heynowski បានប្រគល់ជូនអង្គជំនុំជម្រះ ទៅឲ្យសារមន្ទីរទួលស្លែងវិញ ស្របទៅតាមបំណងប្រាថ្នារបស់គាត់។ ដូចលោកបានបញ្ជាក់នៅក្នុងលិខិតរបស់លោកស្រាប់ ឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនោះ បានប្រគល់ជូនសារមន្ទីរទួលស្លែងរួចហើយកាលពីខែធ្នូ ឆ្នាំ២០១៦។ ឯកសារដែលនៅសេសសល់ រួមមានសៀវភៅកំណត់ត្រាអ្នកជាប់ឃុំប្រចាំថ្ងៃពណ៌ទឹកក្រូចមួយក្បាលដែលសរសេរដោយដៃ សន្លឹករូបថត និងរូបថតអ្នកជាប់ឃុំមួយចំនួន រូបថតព្រះបរមរតនកោដ្ឋ នរោត្តមសីហនុ មួយសន្លឹក និងចម្លើយសារភាពនៅលើគម្របសៀវភៅមួយសន្លឹកដោយមានភ្ជាប់នូវរូបថតអ្នកជាប់ឃុំ។

បន្ទាប់ពីទទួលបានលិខិតរបស់លោក ខ្ញុំបានជូនដំណឹងដល់ភាគីនានាថា អង្គជំនុំជម្រះមានបំណងបញ្ជូនឯកសាររបស់លោកសាស្ត្រាចារ្យ Heynowski ទៅសារមន្ទីរទួលស្លែងវិញ ប្រសិនបើពុំមានការជំទាស់ណាមួយដែលសមស្របទេនោះ។ ទាំងក្រុមមេធាវីការពារក្តី នួន ជា និងក្រុមមេធាវីការពារក្តី ខៀវ

សំផន បានជំទាស់ចំពោះការបញ្ជូនឯកសារទាំងនោះចេញពី អ.វ.ត.ក. មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។ មេធាវីការពារក្តី នួន ជា ក៏បានលើកនូវបញ្ហាមធ្យោបាយ និងបែបបទក្នុងការចូលពិនិត្យមើលឯកសារទាំងនោះ ប្រសិនបើឯកសារត្រូវបញ្ជូនទៅរក្សាទុកនៅសារមន្ទីរទួលស្លែង នៅពេលណាមួយនាពេលអនាគត។ សូមលោកមើលកថាខណ្ឌ ២៤ ដល់ ៣០ នៃចម្លើយតបរបស់មេធាវីការពាក្តី នួន ជា ដែលបានភ្ជាប់មកជាមួយជាឯកសារយោង។

ខ្ញុំក៏បានស្នើសុំមតិយោបល់ពីអង្គភាពបណ្ណសារនៃ អ.វ.ត.ក. អំពីបញ្ហាថា តើឯកសាររបស់លោកសាស្ត្រាចារ្យ Heynowski មានសភាពពុកផុយជាងមុនដែរឬទេ ចាប់តាំងពីបញ្ជូនមកដល់ អ.វ.ត.ក. និងថាតើការបន្តទុកឯកសារទាំងនោះនៅ អ.វ.ត.ក. អាចនឹងនាំឱ្យកាន់តែពុកផុយដែរឬយ៉ាងណា។ អង្គភាពបណ្ណសារបានជូនដំណឹងដល់ខ្ញុំថា រូបថតឬស្នឹករូបថតអ្នកជាប់ឃុំ មានសភាពពុកផុយជាងមុន ប៉ុន្តែមិនអាចផ្តល់យោបល់ថាតើវាបណ្តាលមកពីសារធាតុគីមី ឬអាស៊ីតនៅលើឯកសារទាំងនោះ ឬយ៉ាងណាទេ។ អង្គភាពបណ្ណសារក៏បានបញ្ជាក់ផងដែរថា ទោះបីជាអង្គភាពនេះអាចបន្តថែរក្សាឯកសារទាំងនោះទៅតាមលក្ខណៈដែលបានរៀបរាប់ជូនយ៉ាងណាក៏ដោយ ក៏អង្គភាពបណ្ណសារពុំមានជំនាញបច្ចេកទេស ឬឯកទេសដើម្បីថែរក្សា ឬអភិរក្សឯកសារទាំងនោះឡើយ។ សូមលោកមើលកថាខណ្ឌ ២, ៣, ៤ និង ៨ នៃចម្លើយតបរបស់អង្គភាពបណ្ណសារនៃ អ.វ.ត.ក. ដែលមានភ្ជាប់មកជាមួយជាឯកសារយោង។

មុនពេលអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសម្រេចចុងក្រោយអំពីថាតើ ត្រូវបញ្ជូនឯកសាររបស់លោកសាស្ត្រាចារ្យ Heynowski ទៅសារមន្ទីរទួលស្លែងវិញនៅពេលនេះឬយ៉ាងណានោះ ខ្ញុំសូមស្នើសុំឱ្យលោកឆ្លើយតបទៅនឹងបញ្ហាមួយចំនួនដែលបានលើកឡើងដោយអង្គភាពបណ្ណសារ អ.វ.ត.ក. និងមេធាវីការពារក្តី នួន ជា ពោលគឺខ្ញុំស្នើសុំឱ្យលោកផ្តល់យោបល់លើបញ្ហាខាងក្រោមនេះ៖

១. ផ្អែកលើបទពិសោធន៍របស់លោកជាមួយនឹងប្រភេទឯកសារស្រដៀងគ្នានេះ ក៏ដូចជាការសង្កេតឃើញរបស់បុគ្គលិកលោកទៅលើឯកសាររបស់លោកសាស្ត្រាចារ្យ Heynowski តើអាចមានឬគួរចាត់វិធានការបែបណាខ្លះ (បន្ថែមទៅលើវិធានការដែលមានស្រាប់រួចហើយនៅចំពោះមុខ អ.វ.ត.ក.) ដើម្បីថែររក្សា ការពារឯកសាររបស់លោកសាស្ត្រាចារ្យ Heynowski កុំឱ្យពុកផុយខ្លាំងជាងនេះទៀត?

២. ថាតើ សារមន្ទីរទួលស្លែងមានធនធាននិងជំនាញ ដើម្បីអនុវត្តវិធានការបន្ថែមទាំងនោះនៅឯសារមន្ទីរទួលស្លែងដែរឬទេ (ការថែរក្សានិងការជួសជុល ប្រសិនបើចាំបាច់)

៣. ប្រសិនបើឯកសាររបស់លោកសាស្ត្រាចារ្យ Heynowski ត្រូវបានបញ្ជូនទៅសារមន្ទីរទួលស្លែងវិញ នៅពេលណាមួយខាងមុខនោះ៖

ក. តើភាគីនៃសំណុំរឿងអាចចូលទៅពិនិត្យមើលឯកសារទាំងនោះដោយរបៀបណា? (សូមមើល កថាខណ្ឌ ២៧ នៃចម្លើយតបរបស់មេធាវីការពារក្ដី នួន ជា)

ខ. តើសារមន្ទីរទួលស្លែងមានគោលការណ៍អ្វីខ្លះពាក់ព័ន្ធនឹងដំណើរការនៃការការពារ និងថែរក្សាឯកសារ (ការការពារបូរណភាពឯកសារពីការធ្វើឱ្យខូចខាតទ្រង់ទ្រាយ ដែលអាចបង្កឡើងដោយសាធារណជន)?

គ. តើការដាក់បង្ហាញឯកសារទាំងនោះជាសាធារណៈ នឹងរារាំងដល់ការស្នើសុំចូលពិនិត្យមើលឯកសារទាំងនោះពីភាគីនៃសំណុំរឿងក្ដីដែរឬទេ? ប្រសិនបើរារាំងមែន តើក្នុងកម្រិតណា?

អង្គជំនុំជម្រះតុលាការកំពូលនឹងទទួលយុត្តាធិការលើសំណុំរឿង ០០២/០២ នៅពេលទទួលបានការជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។ នាពេលបច្ចុប្បន្ននេះ ការជូនដំណឹងអំពីបណ្ដឹងសាទុក្ខគឺនឹងធ្វើឡើងនៅដើមខែកក្កដាខាងមុខនេះ។ ហេតុដូច្នេះ ប្រសិនបើលិខិតឆ្លើយតបរបស់លោកនឹងផ្ញើមកនៅក្រោយកាលបរិច្ឆេទនេះ ខ្ញុំស្នើឱ្យលោកទាក់ទងផ្ទាល់ទៅកាន់ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូលតាមអាសយដ្ឋានអ៊ីម៉ែល phan.theoun@eccc.gov.kh ។

សូមជូនភ្ជាប់មកជាមួយនូវឯកសារភ្ជាប់ចំនួន ២ ៖

- ចម្លើយតបរបស់ នួន ជា ទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E443/12/1)។
- ចម្លើយតបរបស់អង្គភាពបណ្ណសារ អ.វ.ត.ក. ទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E443/14)។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកចំពោះកិច្ចសហការរបស់លោកលើបញ្ហានេះ។

**សូមលោកទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។**

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**